ពូជស្រូវសុទ្ធល្អ ជាមូលដ្ឋានគ្រឹះក្នុងការផលិតពូជស្រូវ ព្រោះគ្រាប់ពូជសុទ្ធល្អមានគុណភាពខ្ពស់ ជាកត្តាធ្វើអោយការបង្កបង្កើនផលស្រូវរបស់គាត់ទទួលបាននូវទិន្នផលខ្ពស់ និងមានតំលៃថ្លៃជាងពូជស្រូវដែលមិនសុទ្ធ ហើយអាចនាំទៅលក់នៅទីផ្សារអន្តរជាតិថែមទៀតផង ។ ប្រជាកសិករយើងនឹងទទួលប្រាក់ចំណូលសំរាប់សេដ្ឋកិច្ចគ្រួសារ ។ ដូចនេះកសិករយើងគប្បីស្វែងយល់នឹងយកចិត្តទុកដាក់អំពីរបៀបផលិតពូជសុទ្ធល្អ នឹងធ្វើការថែទាំឱ្យបានហ្មត់ចត់ ។

## ១. ការរៀបចំដី :

ការរៀបចំដីសំរាប់ធ្វើថ្នាលសំណាបយើងត្រូវធ្វើយ៉ាងណាឱ្យនៅឆ្ងាយពីពូជផ្សេងៗទៀត ។ ម្យ៉ាងទៀតការរៀបចំដីស្ទូងវិញ ត្រូវភ្ជួររាស់អោយបានច្រើនដង ក្នុងមួយដងៗ មានរយៈពេល ៧ ទៅ ១៥ ថ្ងៃ ដើម្បីឱ្យស្មៅ និងពូជផ្សេងៗទៀតដុះ រួចភ្ជួររាស់ជាលើកចុងក្រោយទើបពង្រាបដីអោយបានស្មើល្អ ។

## ២. ការជ្រើសរើសគ្រាប់ពូជ :

គ្រាប់ពូជដែលល្អត្រូវមានលក្ខណៈដូចខាងក្រោម :

- គ្រាប់ពូជដែលសុទ្ធល្អ មិនលាយឡំពូជផ្សេងៗ ឬគ្រាប់ស្មៅ ។
- ពូជដែលផ្តល់ទិន្នផលខ្ពស់រយៈពេលលូតលាស់ខ្លី
- មានប្រភពច្បាស់លាស់
- គ្រាប់ពូជត្រូវមានទំហំគ្រាប់ប៉ុនៗគ្នា ពណ៌ដូចគ្នា ហើយមានដំណុះពី ៩០ % ឡើងទៅ ។
- គុណភាពអង្ករល្អមានតំលៃខ្ពស់លើទីផ្សារ ។

## ៣. ការសំអាតឧបករណ៍នៅពេលត្រាំគ្រាប់ពូជ :

ជាដំបូងនៅមុនពេលត្រាំគ្រាប់ពូជ អ្នកត្រូវសំអាតឧបករណ៍ដូចជា : ពាង, ធុង , បាវ, ការ៉ុង ដែលត្រូវត្រាំគ្រាប់ពូជនោះអោយបានស្អាតល្អ ជៀសវាងមានគ្រាប់ពូជផ្សេងៗទៀត នៅជាប់នឹងឧបករណ៍នោះ ។

## ៤. ការបន្សុទ្ធពូជនៅពេលស្រូវកំពុងដុះលូតលាស់ :

នៅដំណាក់កាលស្រូវកំពុងលូតលាស់ ការបន្សុទ្ធពូជនេះ វាមានសារៈសំខាន់ណាស់ ព្រោះយើងអាចពិនិត្យឃើញពីលក្ខណៈខុសគ្នា នៃការដុះលូតលាស់របស់ស្រូវ ។ ពេលវេលាដែលត្រូវធ្វើការបន្សុទ្ធនៅក្នុងដំណាក់កាលចេញកួរ ពីព្រោះថ្ងៃខែនៃការចេញកួរនេះ អាចកំណត់បានពីពូជដែលមានអាយុកាលខ្លី និងដែលមានអាយុកាលវែង ។ ការបន្សុទ្ធពូជដោយសំរិតសំរាំងនេះ អាចធ្វើទៅបាននៅគ្រប់ដំណាក់កាលរបស់ដំណាំស្រូវដែលមានលក្ខណៈខុសគ្នាដូចជា : កំពស់ , ពណ៌ដើម , ដើម , ពណ៌ស្លឹក និងពណ៌គ្រាប់ , កំណកំណើតកួរ ថ្ងៃចេញផ្កា , ទំហំស្លឹក , ទំហំគ្រាប់ , ការដុះកន្ទុយរបស់គ្រាប់ស្រូវ ។ល។

ប្រសិនបើយើងពិនិត្យឃើញថា ដើមណាដែលមានលក្ខណៈខុសប្លែកពីពូជដែលអ្នកចង់បាន ត្រូវដកចេញឬកាត់ចោលតែម្តង ដើម្បីជៀសវាងមានពូជលាយឡំគ្នា ។

## ៥. ការបន្សុទ្ធពូជនៅពេលច្រូតកាត់បោកបែន :

ដើម្បីជៀសវាងកុំអោយមានពូជផ្សេងៗនៅជាប់នឹងឧបករណ៍ដែលទុកសំរាប់ធ្វើការបោកបែន នៅពេលច្រូតកាត់ ចាំបាច់ត្រូវសំអាតឧបករណ៍ទាំងនោះអោយបានស្អាតជាមុនសិន រួចហាលឱ្យ